# សេចក្តីជូនដំណឹង

ដើម្បីចូលរួមពង្រឹងការត្រួតពិនិត្យ និងការគ្រប់គ្រងឡចំហាយនៅតាមរោងចក្រសហគ្រាសឲ្យមានប្រសិទ្ធភាព និងមានវិជ្ជាជីវៈច្បាស់លាស់ ដែលអាចធានាបាននូវសុវត្ថិភាពខ្ពស់ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) សហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម (MOIH) និងក្រសួងការងារបណ្តុះបណ្តាល វិជ្ជាជីវៈ (MOLVT) នឹងរៀបចំវគ្គអប់រំផ្សព្វផ្សាយស្តីពីសុវត្ថិភាពនិងការគ្រប់គ្រងឡចំហាយ ជូនទៅដល់សមាជិករបស់ខ្លួន ដោយធ្វើការបែងចែកជា៣វគ្គ និង៣តំបន់នៃខេត្តក្រុងដូចដែលមានកាលបរិច្ឆេទ និងទីកន្លែងខាងក្រោម៖

១. ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ចាប់ពីម៉ោង៨:៣០ព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់ នៅសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ដែលនឹងមានតំណាងរោងចក្រសហគ្រាស និងអ្នកកាន់ការងារផ្នែកឡចំហាយ មកពីតំបន់ទីក្រុងភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តកំពង់ចាម។

២. ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ចាប់ពីម៉ោង៨:៣០ព្រឹក ដល់ម៉ោង១២ ថ្ងៃត្រង់ (ទីកន្លែងនឹងបញ្ជាក់ជូនតាមក្រោយ) ដែលនឹងមានតំណាងរោងចក្រសហគ្រាស និងអ្នកកាន់ការងារផ្នែកឡចំហាយ នៅតំបន់នៃខេត្តកំពង់សោម ក្រុងព្រះសីហនុ។

៣. ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ ចាប់ពីម៉ោង៨:៣០ព្រឹក ដល់ម៉ោង១២ ថ្ងៃត្រង់ (ទីកន្លែងនឹងបញ្ជាក់ជូនតាមក្រោយ)ដែលនឹងមានតំណាងរោចក្រសហគ្រាស និងអ្នកកាន់ការងារផ្នែកឡចំហាយ នៅតំបន់នៃខេត្តស្វាយរៀង ក្រុងបាវិត។

ភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា GARMENT MANUFACTURERS ASSOCIATION IN CAMBODIA សមាគមកាត់ដេរនៅកម្ពុជា

**បញ្ជាក់**

សំរាប់ព័ត៌មានបន្ថែម រឺការចុះឈ្មោះចូលរួម សូមទំនាក់ទំនង៖
លេខាធិការដ្ឋានលេខ ០២៣ ៣០១១៨១ រឺ ០២៣ ៦២២ ៨៨៨៨



តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Trapeang Kul Village, Sangkat Kantouk, Khan Por Sen Chey, Phnom Penh Cambodia.
Tel: (855) 23-88 34 35 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org